# ប្រាសាទខ្នាចទោល

ប្រសិនបើគេនិយាយដល់ប្រាសាទឥដ្ឋនៅតំបន់សំបូរព្រៃគុក គេតែងនឹកឃើញដល់ក្រុមប្រាសាទយាយព័ន្ធ ក្រុមប្រាសាទតោ ក្រុមប្រាសាទសំបូរ ក្រុមប្រាសាទរបងរមាស ក្រុមប្រាសាទត្រពាំងរពាក់ ។ល។ ដ្បិតក្រុមប្រាសាទទាំងនេះ សុទ្ធសឹងជាក្រុមសំខាន់ៗ ហើយប្រាសាទទៀតសោតក៏នៅសល់រូបរាងល្អថែមទៀតផង។ ប៉ុន្តែ ក្រុមប្រាសាទមួយចំនួនដែលស្ថិតនៅក្នុងបរិវេណក្រុងឦសានបុរ (២ គ.ម. x ២ គ.ម.) ដែលស្ថិតនៅខាងលិច អ្នកទេសចរណ៍ពុំសូវចាប់អារម្មណ៍ឡើយ លើកលែងតែអ្នកស្រាវជ្រាវប៉ុណ្ណោះ។ ដូច្នេះហើយ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញអំពីក្រុមប្រាសាទមួយដែលស្ថិតនៅក្នុងបរិវេណក្រុងបុរាណ ដែលមានឈ្មោះថា "ក្រុមប្រាសាទខ្នាចទោល"។ តើក្រុមប្រាសាទនេះមានប្រវត្តិ និងលក្ខណៈបែបណាខ្លះ?

ក្រុមប្រាសាទខ្នាចទោល មានទីតាំងស្ថិតនៅក្នុងបរិវេណក្រុងឦសានបុរ (ផ្នែកខាងជើង)។ តាមរយៈការស្រាវជ្រាវកន្លងមកដោយសាកលវិទ្យាល័យវ៉ាសេដា គេបានរកឃើញប្រាសាទនៅក្នុងបរិវេណក្រុងបុរាណនេះប្រមាណ ១០០ ប្រាសាទ (ភាគច្រើនបាក់បែកអស់ទៅហើយ)។ យោងទៅតាមទិន្នន័យរូបថតពីលើអាកាស និងការចុះស្រាវជ្រាវផ្ទាល់ដល់ទីតាំង (ចន្លោះឆ្នាំ២០០៣ ដល់ ២០១៤) គួបផ្សំនឹងទិន្នន័យ Lidar (ថតក្នុងឆ្នាំ២០១៣) បានបង្ហាញយ៉ាងច្បាស់ថា បរិវេណខាងក្នុងរបស់ក្រុងឦសានបុរ រៀបចំឡើងជាប្រព័ន្ធក្រឡាចត្រង្គទម្រង់ ៨ ក្រឡាស្មើៗគ្នា ដែលបានមកពីការផ្គុំរបស់ខ្សែផ្លូវមួយចំនួនបីរត់ស្របគ្នាក្នុងអ័ក្សលិច-កើតខ្វែងជាមួយផ្លូវបីផ្សេងទៀតដែលរត់ស្របនៅលើអ័ក្សជើង-ត្បូង។ ប្រាសាទដែលស្ថិតនៅក្នុងបរិវេណកំពែងក្រុងនេះ ភាគច្រើនសង់ឡើងដោយយកអ័ក្សផ្លូវទាំងនេះជាគោល ក្នុងការវាស់ចែកធ្លារបស់ប្រាសាទពីក្រុមមួយទៅក្រុមមួយទៀត។ ជាក់ស្តែង ក្រុមប្រាសាទខ្នាចទោល (M103) គឺជាគន្លងផ្លូវរបៀងខាងជើង ដែល ផ្តើមចេញពីកំពែងខាងលិចរត់ឆ្លងកាត់តាមប្រាសាទសំខាន់ៗដូចជា M105, M97, M118, M65, M66 និងចុងក្រោយភ្ជាប់ទៅនឹងទំនាបនៃអូរគ្រូកែ។ ក្នុងនោះ ចាប់ពីច្រកចូលរហូតដល់ប្រាសាទខ្នាចទោល (M103) មានគន្លងមួយចំនួនបាត់ស្នាមខ្លះ ប៉ុន្តែគេអាចសន្និដ្ឋានថា ជាគន្លងផ្លូវ ដ្បិតសំអាងទៅលើទីតាំងរបស់ស្រះ និងទីតាំងទួលប្រាសាទ។ ដោយឡែក ចាប់ពីរានហាលមុខខាងកើតនៃប្រាសាទខ្នាចទោល គន្លងផ្លូវនៅសល់តឹកតាងបានច្បាស់លាស់ណាស់ ដោយរត់ឆ្លងកាត់តាមខាងត្បូងនៃបឹងថ្កាស ភ្ជាប់ត្រង់ទៅនឹងកំពែងខាងត្បូងនៃប្រាសាទ M66 និងបន្តទៅទំនាបអូរគ្រូកែ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ក្រុមប្រាសាទខ្នាចទោល មានប្រាសាទសរុបចំនួន ៤ ដែលសង់ឡើងនៅប្របមាត់ស្រះខ្នាចទោលនៅក្នុងរាជធានីឦសានបុរ ហើយក្នុងចំណោមប្រាសាទចំនួន ៤ គឺមានប្រាសាទចំនួន ១ មានប្លង់ជារាងប្រាំបីជ្រុង (សព្វថ្ងៃអាជ្ញាធរជាតិសំបូរព្រៃគុកបានចុះបញ្ជីតាមប្រព័ន្ធថ្មីហៅថា KT1) (រូបលេខ ១ ដល់ ៤)។ នៅក្នុងឆ្នាំ២០២២ អាជ្ញាធរជាតិសំបូរព្រៃគុក បានធ្វើកំណាយស្រាវជ្រាវនៅក្រុមប្រាសាទខ្នាចទោល ក្នុងគោលបំណងស្វែងយល់អំពីស្ថាបត្យកម្ម នគរោបនីយកម្ម និងទេសភាពបុរាណរបស់ប្រាសាទដែលបានកប់ក្នុងដី និងដើម្បីពង្រីកនិងកែលម្អខ្សែទស្សនាចរណ៍ថ្មីស្របតាមផែនការមេនៃកិច្ចអភិរក្ស និងអភិវឌ្ឍរបស់អាជ្ញាធរជាតិសំបូរព្រៃគុក។ ជាលទ្ធផលនៃការធ្វើកំណាយតាមបែបបុរាណវិទ្យា គេបានរកឃើញថា ប្រាសាទទាំងបួននៃក្រុមប្រាសាទខ្នាចទោល គឺសាងសង់ឡើងដោយមានកសិន្ធុព័ទ្ធជុំវិញនៅជ្រុងទាំងបី ពោល គឺខាងកើត ខាងត្បូង និងខាងជើង (ខាងលិច ជាស្រះធំដែលគេជីក) ហើយមានកំពែងធ្វើអំពីឥដ្ឋដែលមានច្រកចូលនៅទិសខាងត្បូង និងខាងជើង។ ក្រុមជំនាញរបស់អាជ្ញាធរជាតិសំបូរព្រៃគុក បានសន្និដ្ឋានថា ក្រុមប្រាសាទខ្នាចទោលអាចសង់ឡើងជាបីដំណាក់កាល ហើយតាមរយៈសិល្បៈនិងស្ថាបត្យកម្មដែលរកឃើញ គេគិតថាមានអាយុកាលនៅពាក់កណ្ដាលស.វ.ទី៧ ស្ថិតនៅរវាងចុងរចនាបថសំបូរព្រៃគុក និងដើមរចនាបថព្រៃក្មេង ពោល គឺមានអាយុកាលប្រហាក់ប្រហែលក្រុមប្រាសាទយាយព័ន្ធ ក្រុមប្រាសាទសំបូរ និងប្រាសាទមួយចំនួនទៀតនៅក្រៅតំបន់សំបូរព្រៃគុក ដូចជា ប្រាសាទស្រីគ្រប់ល័ក្ខណ (ភ្នំបាសិត) ជាដើម។

ទោះបីជាយ៉ាងណា វាពិបាកទៅរួចណាស់ដែលសន្និដ្ឋានថា វត្ថុសិល្បៈ និងស្ថាបត្យកម្មផ្ដល់អាយុកាលនៅចុងរចនាបថសំបូរព្រៃគុក និងដើមរចនាបថព្រៃក្មេង ដ្បិតផ្ដែរទ្វារចំនួន ២ ដែលរកឃើញនៅក្រុមប្រាសាទខ្នាចទោល សុទ្ធសឹងតែផ្ដល់ទិន្នន័យឱ្យយើងដឹងថា វាជាសិល្បៈស្ទើរតែចាស់ជាងរចនាបថសំបូរព្រៃគុក (រចនាបថថាឡាបរិវ៉ាត់, ផ្ដែររកឃើញនៅប្រាសាទ KT2) និងរចនាបថសំបូរព្រៃគុក (ផ្ដែររកឃើញនៅប្រាសាទ KT1)។ ផ្ដែរទ្វារទី១ (រូបលេខ៥) រកឃើញនៅប្រាង្គ KT2 បង្ហាញអំពីផ្ដែរទ្វារមួយមានការរបកចម្លាក់ជាច្រើន ប៉ុន្តែយើងអាចនៅមើលឃើញថាស្នាមចម្លាក់សងខាង គឺជាចម្លាក់រូបសត្វមករខ្ជាក់ក្បាច់បន្ទាត់ធ្នូដែលមានរាងកោងមកប្រសព្វគ្នាជាមួយក្បាច់ត្បូង (រាងវង្វង់) នៅចំកណ្ដាល ដែលជាលក្ខណៈទូទៅដូចផ្ដែរទ្វារមួយចំនួនរកឃើញនៅតំបន់ថាឡាបរិវ៉ាត់ ពោល គឺអាយុកាលទំនងចាស់ជាងរចនាបថសំបូរព្រៃគុកបន្តិច (អាចស្ថិតនៅក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី១ ឬព្រះបាទមហេន្ទ្រវរ្ម័ន)។ ដូចយើងដឹងច្បាស់ហើយថា សិលាចារឹកចំនួន ២ រកឃើញនៅតំបន់សំបូរព្រៃគុក (សិលាចារឹកប្រាសាទស្រីគ្រប់ល័ក្ខណ K.151 និងសិលា

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ចារឹកប្រាសាទជ្រៃ K.149) សុទ្ធតែបានរៀបរាប់ថា មន្ត្រីនរសិង្ហគុប្ត និងអាចារ្យម្នាក់ បានបម្រើឱ្យស្តេចចំនួន ៣ អង្គបន្តបន្ទាប់គ្នា ពោល គឺព្រះបាទភវវរ្ម័នទី១ ព្រះបាទមហេន្ទ្រវរ្ម័ន និងព្រះបាទឦសានវរ្ម័នទី១។ តឹកតាងនេះ អាចបញ្ជាក់ថា ក្រុងឦសានបុរ ទំនងមានសកម្មភាពឡើងតាំងពីរជ្ជកាលព្រះបាទភវវរ្ម័នទី១ ឬព្រះបាទមហេន្ទ្រវរ្ម័នមកម្ល៉េះ។ ម្ល៉ោះហើយ សំណង់ប្រាសាទរបស់ស្តេចទាំងពីរអង្គ ប្រហែលជាមានខ្លះនៅតំបន់សំបូរព្រៃគុក ដូចជា ប្រាសាទដងរែក (N19) និងប្រហែលប្រាសាទខ្នាចទោល ប្រាង្គ KT2 នេះតែម្តង។ ចំណែក ផ្តែរទ្វារទី២ (រូបលេខ៦) រកឃើញនៅប្រាសាទដែលមានរាងប្រាំបីជ្រុង (KT1) ហើយផ្តែរនេះបានបាក់បែកនៅសល់ត្រឹមពាក់កណ្តាលប៉ុណ្ណោះ ប៉ុន្តែចម្លាក់នៅមានលក្ខណៈច្បាស់ល្អបង្ហាញអំពីចម្លាក់ទេពជិះលើសត្វមករ បែរចូលក្នុងខ្នាក់ក្បាច់បន្ទាត់ធ្នូរាងកោងដែលមានក្បាច់ត្បូងលម្អដោយទេពប្រណម្យនៅខាងក្នុង ពោល គឺជាលក្ខណៈសុទ្ធសាធនៃរចនាបថសំបូរព្រៃគុក មិនអាចជាសិល្បៈនៅចុងរចនាបថសំបូរព្រៃគុក ឬដើមរចនាបថព្រៃក្មេងនោះទេ។ យើងសង្កេតឃើញថា ក្នុងចំណោមប្រាសាទទាំង ៤ សិល្បករបានសាងប្រាសាទ KT1 ដែលមានរាងប្រាំបីជ្រុងប្រឈមខ្ញាំងទៅនឹងមាត់ស្រះធំ (ភាគខាងជើង) នៅតំបន់ខ្នាចទោល ពោល គឺសាងឡើងអំពីឥដ្ឋ បែរមុខទៅកើត ហើយខាងលិចមានស្រះតូចមួយនិងខាងកើតមានស្រះធំមួយទៀត។ ករណីនេះ ហាក់ដូចជា ការចាប់ផ្តើមសាងសង់ឡើងដំបូងនៅប្រាសាទ KT2 ហើយបន្ទាប់មកគេកសាងប្រាសាទ KT3, KT4 និង KT1។ ពោល វាហាក់ដូចជាប្រាសាទ KT1 ដែលមានរាងប្រាបីជ្រុងនេះ ពុំមែនជាប្រាសាទសំខាន់នៃក្រុមប្រាសាទនេះឡើយ ហើយវាប្រហែលគ្រាន់ជាប្រាសាទរណបដូចក្រុមប្រាសាទយាយព័ន្ធ ក្រុមប្រាសាទសំបូរ និងក្រុមប្រាសាទត្រពាំងរពាក់ដែរ។ ដោយហេតុថា សិលាចារឹកដែលរកឃើញនៅក្នុងប្រាសាទខ្នាចទោលជាបំណែកតូចៗដែលមិនអាចផ្តល់ព័ត៌មានអ្វីបាន យើងពុំអាចស្គាល់ពីព្រះនាមទេពសំខាន់ដែលគេតម្កល់នៅក្នុងក្រុមនេះឡើយ។ ប៉ុន្តែ ដោយហេតុថាពីមុនមក គេធ្លាប់រកឃើញសិវលិង្គនៅទីនោះ អាចឱ្យយើងសន្និដ្ឋានថា ក្រុមប្រាសាទនេះ ក៏ឧទ្ទិសដល់ព្រហ្មញ្ញសាសនា និកាយព្រះសិវដូចក្រុមប្រាសាទនានានៅតំបន់សំបូរព្រៃគុកដែរ។

ជារួមមក ក្រុមប្រាសាទខ្នាចទោល គឺជាទេវស្ថានព្រហ្មញ្ញសាសនាដ៏សំខាន់មួយដែលស្ថិតនៅតាមបណ្តោយផ្លូវដ៏សំខាន់ក្នុងក្រុងឦសានបុរ ហើយអាចកសាងឡើងនៅរវាងដើមស.វ.ទី៧ ចាប់ផ្តើមពីរជ្ជកាលព្រះបាទភវវរ្ម័នទី១ ឬព្រះបាទមហេន្ទ្រវរ្ម័ន និងសាងសង់បន្ថែមក្នុងរជ្ជកាលស្តេចក្រោយៗបន្តទៀត ដូចជាព្រះបាទឦសានវរ្ម័នទី១ ជាដើម។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## ឯកសារយោង

**សាន មួយលី** ២០១៩, *សិក្សាអំពីរចនាសម្ព័ន្ធក្រុងឦសានបុរ*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ នៅ មហាវិទ្យាល័យបុរាណវិទ្យា ជំនាន់ទី២៧, ភ្នំពេញ។

CHHUM Menghong. 2014. *The study on basic structure and urbanism of Khmer ancient city Isanapura*, Doctor thesis, Waseda University, Tokyo.

CŒDÈS, George

1943, 'Quelque precisions sur la fin du Fou-Nan', *BEFEO*, Tome 43, Paris.

1952, *Inscription du Cambodge,*Volume IV, EFEO, Paris.

**អាជ្ញាធរជាតិសំបូរព្រៃគុក**

២០២៣, "របាយការណ៍កំណាយនៅក្រុមប្រាសាទខ្នាចទោល", ផ្សាយនៅក្នុងគេហទំព័រផ្លូវការរបស់អាជ្ញាធរជាតិសំបូរព្រៃគុក https://samborpreikuk.gov.kh/km/article/excavation-of-a-group-of-knaytourl-temples ។

## Abstract

Prasat Khanch Tol is situated along the road from west to east in the Ishanapura city, Sambor Prei Kuk archaeological site. The temple group consists of four sanctuaries, a brick monument, three sanctuaries are squares and one is octagonal temple, facing to the east and surrounded by the rectangular moat. This temple was possibly built in the early 7th century CE in the reign of King Bhavavarman I, Mahendravarman and likely completed it in the reign of King Ishanavarman I. Due to this temple not having information from the inscriptions, it has faced difficulties to recognize the art historical and the role of the temple in religion. However, according to the reliefs on the lintel and the layout of the temple, it has been concluded that Prasat Khach Tol temple group is possibly dedicated to the Hinduism of the Saiva.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១ ៖ ប្រាសាទមានពង់បួនជ្រុងទ្រវែង (KT2)



រូបលេខ២ ៖ ប្រាសាទមានពង់បួនជ្រុងទ្រវែង (KT2)



រូបលេខ៧៖ ប្រាសាទរាងប្រាំបីជ្រុង (KT1) ក្នុងក្រុមប្រាសាទខ្នាចទោល



រូបលេខ៨៖ ប្រាសាទរាងប្រាំបីជ្រុង (KT1) ក្នុងក្រុមប្រាសាទខ្នាចទោល

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៥ ៖ ផ្តែរទ្វាររចនាបថថាឡាបរិវ៉ាត់ រកឃើញនៅប្រាង្គ KT2   (ប្រភព៖ ឯម ភារក្ស)



រូបលេខ២៦៖ ផ្តែរទ្វាររចនាបថសំបូរព្រៃគុក រកឃើញនៅប្រាង្គ KT1   (ប្រភព៖ ឯម ភារក្ស)

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION